**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

JS LAND PLC

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី**
លេខ:២៧៣/០១៧/២៣កជ.អ.ល.

# សេចក្តីប្រកាស
## ស្តីពីលទ្ធផលមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ
## របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី** (**"ជ.អ.ល."**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិក និងសាធារណជនទាំងអស់មេត្តាជ្រាបថា ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី បានប្រារព្ធកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ នៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០២៣ វេលាម៉ោង ៩:០០ នាទី ដល់ម៉ោង ១០:២០ នាទី ដែលប្រព្រឹត្តតាមរយៈសន្និសិទប្រព័ន្ធអនឡាញ Zoom នៅបន្ទប់ប្រជុំ របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី។

វត្តមានរបស់ក្រុមប្រឹក្សាភិបាលនៅក្នុងកិច្ចប្រជុំតាមរយៈសន្និសិទប្រព័ន្ធអនឡាញZoomមានដូចជា៖

| | |
|---|---|
| ១. ឧកញ៉ា កួយ ឡេសាន | ប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធានមហាសន្និបាត |
| ២. លោក Dato' Yap Ting Chiat | នាយកប្រតិបត្តិ/អភិបាលប្រតិបត្តិ |
| ៣. ឧកញ៉ា ម៉េង លី | អភិបាលមិនប្រតិបត្តិ |
| ៤. លោក Yap Maow Jun | អភិបាលមិនប្រតិបត្តិ |
| ៥. លោក Tang Chat Tong | អភិបាលមិនប្រតិបត្តិ |
| ៦. លោក Yap Ting Wui | អភិបាលមិនប្រតិបត្តិ |
| ៧. លោក Dato' Tan Teck Zin | អភិបាលឯករាជ្យ |

កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី មានការចូលរួមពីភាគហ៊ុនិក ចំនួន ១២ នាក់ ដែលបានចូលរួមតាមរយៈសន្និសិទប្រព័ន្ធអនឡាញ Zoom ដែលភាគហ៊ុនសរុបមានចំនួន ២០.០៣៩.២១៩ ភាគហ៊ុន នៃភាគហ៊ុនចុះបញ្ជីសរុបចំនួន ២៥.៧១០.០០០ ដែលមានកូរ៉ុមសរុបចំនួន ៧៧.៩៤% កូរ៉ុម។


ចុះបញ្ជីក្រោមលេខ
Registration No. 00010332

លេខ B២-១០៧ អគារ The Elysee កោះពេជ្រ វិថីកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#B2-107, The Elysee Diamond Island, Koh Pich Street, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 010 88 66 99
E-mail: info@jslandplc.com, Website: www.jslandplc.com

ក្នុងកិច្ចប្រជុំនេះ ភាគហ៊ុនិកបានបោះឆ្នោតស្របតាមការស្នើដោយទទួលបានលទ្ធផលដូចខាងក្រោម៖

| ល.រ | សេចក្ដីសម្រេចការបោះឆ្នោត | ចំនួនភាគហ៊ុន (យល់ស្រប) | ភាគរយ (យល់ស្រប) | ចំនួនភាគហ៊ុន (មិនបានបោះឆ្នោត) | ភាគរយ (មិនបានបោះឆ្នោត) |
|---|---|---|---|---|---|
| ក | បានបោះឆ្នោតអនុម័ត និងយល់ព្រម ប្រគល់សិទ្ធិអំណាច ពេញលេញជូន ក្រុមប្រឹក្សាភិបាល ដើម្បី (i) ចុះកិច្ចសន្យា អនុវត្ត និងចុះហត្ថលេខា លើរាល់កិច្ចសន្យា និង/ឬ កិច្ចព្រមព្រៀងគ្រប់ប្រភេទ (ដែលរួមមានជាអាទិ៍ កិច្ចព្រមព្រៀងកម្ចី កិច្ចសន្យាទិញ និង/ឬលក់ដី ។ល។) (**"កិច្ចព្រមព្រៀង"**) ដែលកិច្ចព្រមព្រៀងនីមួយៗមានតម្លៃរហូតដល់ត្រឹមចំនួន **៥.០០០.០០០ ដុល្លារអាមេរិក** ក្នុងនាម និងជាតំណាងឲ្យក្រុមហ៊ុន ជ.អ.ល (ii) ធ្វើនូវរាល់កិច្ចការ និង/ឬសកម្មភាពនានា ដើម្បីផ្ដល់អានុភាព ដល់ការចុះកិច្ចសន្យា ការអនុវត្ត និងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងខាងលើនេះ និង (iii) ចាត់រាល់វិធានការ និង/ឬធ្វើនូវរាល់សកម្មភាពនានា ដែលក្រុមប្រឹក្សាភិបាលយល់ថាចាំបាច់ ឬសមស្រប សម្រាប់គោលបំណងខាងលើ។ | ២០.០៣៩.១៩៩ | ៩៩.៩៩៩៩% | ២០ | 0.0001% |
| ខ | បានបោះឆ្នោតអនុម័ត និងយល់ព្រម ឱ្យក្រុមប្រឹក្សាភិបាល ប្រគល់សិទ្ធិអំណាចបន្ត ដល់ (i) លោកឧកញ៉ា កួយ ឡេសាន ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ និង (ii) លោក Dato Yap Ting Chiat នាយកប្រតិបត្តិ/អភិបាលប្រតិបត្តិរបស់ក្រុមហ៊ុន ជ.អ.ល (**"អ្នកតំណាង"**) ក្នុងការ (ក) ចុះកិច្ចសន្យា អនុវត្ត និងចុះហត្ថលេខា លើរាល់កិច្ចសន្យា និង/ឬ កិច្ចព្រមព្រៀងគ្រប់ប្រភេទ (ដែលរួមមានជាអាទិ៍ កិច្ចព្រមព្រៀងកម្ចី កិច្ចសន្យាទិញ និង/ឬលក់ដី ។ល។) (**"កិច្ចព្រមព្រៀង"**) ដែលកិច្ចព្រមព្រៀងនីមួយៗមានតម្លៃរហូតដល់ត្រឹមចំនួន **២.០០០.០០០ ដុល្លារអាមេរិក** ក្នុងនាម និងជាតំណាងឲ្យក្រុមហ៊ុន ជ.អ.ល (ខ) ធ្វើនូវរាល់កិច្ចការ និង/ឬសកម្មភាពនានា ដើម្បីផ្ដល់អានុភាព ដល់ការចុះកិច្ចសន្យា ការអនុវត្ត និងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងខាងលើនេះ និង (គ) ចាត់រាល់វិធានការ និង/ឬធ្វើនូវរាល់សកម្មភាពនានា ដែលអ្នកតំណាងយល់ថាចាំបាច់ ឬសមស្រប សម្រាប់គោលបំណងខាងលើ។ | ២០.០៣៩.១៩៩ | ៩៩.៩៩៩៩% | ២០ | 0.0001% |

សម្រេចជាលទ្ធផល ភាគហ៊ុនិកភាគច្រើនយល់ព្រមលើសំណើទាំងអស់ខាងលើ។ អង្គមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ បានបញ្ចប់នៅវេលាម៉ោង ១០:២០ នាទីព្រឹក នៅថ្ងៃខែឆ្នាំដដែល។

អាស្រ័យហេតុនេះ សេចក្តីសម្រេចត្រូវបានអនុម័ត។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិក និងសាធារណៈជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១១ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០២៣

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី**